ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០០៦
# នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# សន្ទរកថាបើកកម្មវិធីរបស់
# ឯកឧត្តម គាត ឈន់
# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សៀមរាប ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៧**

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

ខ្ញុំមានកិត្តិយស និង សេចក្តីរីករាយដែលស្ថិតនៅទីនេះជាមួយលោកជំទាវ ឯកឧត្តម លោកស្រី អស់លោកនៅក្នុងពិធីដ៏មានសារសំខាន់ស្តីពីការត្រួតពិនិត្យប្រចាំឆ្នាំលើកទី ២ លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។ ខ្ញុំសូមសំដែងនូវកត្តញ្ញូតាធម៌ជូនចំពោះឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ដែលបានចំណាយពេលដ៏មានតម្លៃ និង កម្លាំងកាយចិត្ត ដើម្បីចូលរួមក្នុងកម្មវិធីត្រួតពិនិត្យប្រចាំឆ្នាំនេះ ជាពិសេសថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ចំពោះការចូលរួម និង គាំទ្រយ៉ាងសកម្មនៅក្នុងកិច្ចការនេះ ។ ខ្ញុំក៏សូមសំដែងនូវអំណរគុណជាពិសេសចំពោះក្រុមការងារបច្ចេកទេសនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការកែទម្រង់ និង គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ចំពោះកិច្ចខិតខំប្រឹងប្រែង និង ការរៀបចំនូវកម្មវិធីត្រួតពិនិត្យប្រចាំឆ្នាំនេះ ។

ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីបញ្ជាក់សាជាថ្មីម្តងទៀត នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះកម្មវិធីកំណែទម្រង់នេះ ដែលបានបន្តរឹងមាំដោយសារតែការគាំទ្រប្រកបដោយចីរភាពពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័ននីតិបញ្ញត្តិ ។ ខ្ញុំសូមអះអាងថា សហការីនៅគណៈរដ្ឋមន្ត្រីរបស់ខ្ញុំបានយល់ដឹងនូវផែនការ និងវឌ្ឍនភាពរបស់យើង ហើយជាលទ្ធផលគឺកម្មវិធីរបស់យើងបន្តនូវការទទួលផលប្រយោជន៍ពីការជម្រុញលើកទឹកចិត្ត និងការគាំទ្រយ៉ាងសកម្ម និងការចូលរួមសកម្មភាពនេះ ។ ជាងនេះទៀត មនសិការ និងការចែករំលែកនូវ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការយល់ដឹងរបស់អ្នកពាក់ព័ន្ធ ជាពិសេសក្នុងចំណោមថ្នាក់ដឹកនាំជាន់ខ្ពស់ មានការកើនឡើងដោយសារតែបានទទួលព័ត៌មានជាប់ជាប្រចាំ និង ការចូលរួមខ្លាំងជាងមុនរបស់ខ្លួននៅក្នុងកម្មវិធី ។ ជាលទ្ធផល សកម្មភាព និងជំហានជាលំដាប់លំដោយរបស់យើងកាន់តែមានភាពច្បាស់លាស់ជាងមុន និងមានអត្ថន័យជ្រាលជ្រៅចំពោះអ្នកពាក់ព័ន្ធ ដែលធ្វើឱ្យកម្មវិធីកំណែទម្រង់អាចសម្រេចបាននូវលទ្ធផលជាក់លាក់ ។ ខ្ញុំមានជំនឿថាការប្តេជ្ញាចិត្តភាពជាម្ចាស់ ការទទួលខុសត្រូវ និង ទំនុកចិត្តរបស់យើងនឹងបន្តរីកលូតលាស់ទៅមុខ នៅពេលដែលយើងបានមើលឃើញនូវផលប្រយោជន៍ពីកំណែទម្រង់របស់យើង ។

លើសពីនេះទៅទៀត វាច្បាស់ណាស់ថាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនគ្រាន់តែជាបេះដូងនៃអភិបាលកិច្ចល្អតែប៉ុណ្ណោះទេ ប៉ុន្តែវាជាយានដ៏មានសារសំខាន់មួយសម្រាប់សម្រេចនូវគោលដៅគោលនយោបាយរបស់រដ្ឋាភិបាល ជាពិសេសយុទ្ធសាស្ត្រចតុកោណ និង ការអនុវត្តន៍ប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទៀតផង ។ ការធ្វើឱ្យថវិកាមានភាពជឿទុកចិត្តបានជាងមុន មានន័យថាធានានូវចីរភាពលំហូរចូលនៃចំណូល និង ធានានូវលំហូរចេញនូវចំណាយដោយរលូនដើម្បីបំពេញបាននូវតម្រូវការរបស់ក្រសួងចំណាយដើម្បីសម្រេចនូវគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ខ្ញុំគិតថាវាអាចឈឿនបន្តិចក្នុងការប្រកាសនូវជ័យជំនះនៅក្នុងជំហានទីមួយ ដែលយើងនឹងពិភាក្សាគ្នានៅក្នុងកំឡុងពេលត្រួតពិនិត្យពីរថ្ងៃបន្ទាប់ទៅនេះ ខ្ញុំនិយាយដោយមានជំនឿទុកចិត្តថា នៅពេលនេះថវិកាមានភាពគួរឱ្យទុកចិត្តជាងឆ្នាំមុន និងពីរឆ្នាំកន្លង ទៅ ដែលមានន័យថាយើងកាន់តែមានលទ្ធភាពផ្តល់ឱកាសដល់ក្រសួងចំណាយក្នុងការសម្រេចបាននូវគោលដៅគោលនយោបាយរបស់ខ្លួន ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

នៅក្នុងការឈានទៅជំហានបន្តបន្ទាប់ទៀត ដែលនឹងផ្តោតលើគណនេយ្យភាព តម្លាភាព ការវាស់វែង និងតាមដានលទ្ធផលការងារ ខ្ញុំប្រមើលមើលនូវការងារស្មុគស្មាញយ៉ាងច្រើន រួមទាំងវិធានការកែលម្អសមត្ថភាព និងអភិវឌ្ឍបច្ចេកទេសនិងស្ថាប័នដែលក្រសួងចំណាយនឹងត្រូវលើកឡើងដើម្បីធានាបានថា ធនធាន និង អំណាចហិរញ្ញវត្ថុច្រើនជាងមុនដែលយើងបានធ្វើប្រតិភូកម្មទៅឱ្យក្រសួងចំណាយទាំងនោះ ត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ ។ ខ្ញុំមានជំនឿថា លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ដែលជាតំណាងក្រសួង-ស្ថាប័នសំខាន់ៗមួយចំនួនដែលមានវត្តមានទីនេះ នឹងលើកឡើងនូវបញ្ហាទាំងនេះនៅក្នុងបទបង្ហាញរបស់ខ្លួនស្តីពីទស្សនៈរបស់ក្រសួង-ស្ថាប័នចំណាយ ។ អាស្រ័យហេតុនេះ សាររបស់ខ្ញុំចំពោះក្រសួងស្ថាប័នចំណាយគឺថា

ការចូលរួម និង ការសហការពីក្រសួងស្ថាប័នគឺមិនទាន់គ្រប់គ្រាន់ទេ គឺវាទាមទារនូវភាពជាម្ចាស់ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នចំណាយដែលត្រូវតែសកម្មឈានមុខ ដើម្បីធានានូវការអនុវត្តន៍ប្រកបដោយជោគ-ជ័យ នូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

វាមានសារប្រយោជន៍នៅក្នុងការគូសបញ្ជាក់សារជាថ្មីម្តងទៀតថា ភាពជាដៃគូល្អ ការសហការល្អ និង ដំណើរការសម្របសម្រួលល្អ រវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ នៅក្នុងចំណោមក្រសួង-ស្ថាប័ន និង ភ្នាក់ងាររបស់រាជរដ្ឋាភិបាល និងនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ខ្លួនឯង គឺជាចំណុចដ៏សំខាន់នៅក្នុងជោគជ័យ នៃកំណែទម្រង់ដែលមានភាពស្មុគ្រស្មាញនិងគ្រប់ជ្រុងជ្រោយនេះ ។ ទោះជាយ៉ាងណាក៏ដោយ វាមានសារសំខាន់ក្នុងការធានាថាយើងនឹងមិនប្រើប្រាស់ជំនួយ និង ការគាំទ្រ ដែលធ្វើឱ្យបាត់បង់ភាពជាម្ចាស់ និង ការទទួលខុសត្រូវរបស់យើងឡើយ ។ នៅក្នុងបរិការនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និង ទទួលស្គាល់យ៉ាងខ្ពស់ នូវការយកចិត្តទុកដាក់យ៉ាងស្រួចស្រាល់របស់អន្តរជាតិ និង ការគាំទ្រដែលដៃគូអភិវឌ្ឍន៍របស់យើងបានផ្តល់ឱ្យ យើងកន្លងមកសំដៅសម្រេចឱ្យបាននូវគោលដៅដ៏មានមហិច្ឆតានេះ ។ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា អភិក្រមនេះនឹងផ្តល់នូវលទ្ធផលជាផ្លែផ្កា និង មានសារប្រយោជន៍ដល់យើង និងក្លាយជាគំរូដ៏ល្អមួយសម្រាប់ជាមគ្គុទេសក៍នៅក្នុងការអភិវឌ្ឍន៍ ការតាមដាននិងការគ្រប់គ្រងការអនុវត្តន៍ នូវកម្មវិធីកំណែទម្រង់នៅវិស័យដទៃទៀត ។

យើងបានសម្រេចបាននូវវឌ្ឍនភាព និង សមិទ្ធផលមួយចំនួនរួចមកហើយ ប៉ុន្តែយើងនៅមានផ្លូវដ៏វែងឆ្ងាយមួយដែលត្រូវដើរ ហើយយើងក៏ដឹងដែរថាយើងនឹងបន្តប្រឈមមុខនឹងបញ្ហាប្រឈមនានា និង ការសម្រេចចិត្តដ៏លំបាកដែលត្រូវប្រកាន់យក ដែលយើងប្តេជ្ញាចិត្តមិនរាថយឡើយ ។ ប្រការនេះវាបង្ហាញនូវ ការប្តេជ្ញាចិត្ត ភាពជាម្ចាស់ ការទទួលខុសត្រូវ និង ការខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ និង មន្ត្រីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដោយរួមបញ្ចូលទាំងការគាំទ្រ និង ការប្តេជ្ញាចិត្តពីសំណាក់ដៃគូអភិវឌ្ឍន៍របស់យើងផងដែរ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

យើងបានរៀនពីបទពិសោធន៍ និងបានប្រើប្រាស់វាដើម្បីកែលំអការអនុវត្តន៍កម្មវិធីកំណែទម្រង់ដើម្បីទទួលបានលទ្ធផលកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធិភាព។ ខ្ញុំគិតថាកំលាំងខ្លាំងនៃកម្មវិធីរបស់យើងដែលខ្ញុំគួររំលេចនៅទីនេះគឺ៖

១. ការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
២. ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការចូលរួម និងការគាំទ្រយ៉ាងសកម្មពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនានា
៣. ក្របខ័ណ្ឌតាមដាន និងសម្របសម្រួលល្អនៅក្នុងអភិក្រមគ្របដណ្តប់ទូទាំងវិស័យ
៤. ការអនុវត្តន៍តាមជំហានដែលច្បាស់លាស់ និងជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ

កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈគឺជាគោលការណ៍ចំបង នៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ទូទៅ។ សមិទ្ធិផលចក្ខុវិស័យនៅឆ្នាំ ២០១៥ គឺអាស្រ័យលើកាប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតនូវ ក្របខ័ណ្ឌមួយ ដែលមន្ត្រីរាជការអាចរក្សាកំរិតការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយពុំចាំបាច់បន្តពឹងផ្អែកលើការប្រឹក្សា ពីខាងក្រៅ។ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈ គឺកាន់ តែផ្សារភ្ជាប់គ្នា និងគាំទ្រគ្នាទៅវិញទៅមកនៅក្នុងវឌ្ឍនភាពឆ្ពោះទៅរកចក្ខុវិស័យមួយក្នុងការបង្កើនកំរិតនៃ ការគ្រប់គ្រង គណនេយ្យភាព តម្លាភាព និង ការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានសាធារណៈទាំងអស់ និងការអនុវត្តន៍ឱ្យមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធិភាពក្នុងការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ (RS) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) របស់រាជរដ្ឋាភិបាល។

ខ្ញុំជឿជាក់យ៉ាងមុតមាំថាការត្រួតពិនិត្យប្រចាំឆ្នាំលើកទី ២ នេះជាឱកាសដ៏មានសារៈសំខាន់សំរាប់យើង ទាំងអស់គ្នា ក្នុងការចែករំលែកនូវបទពិសោធន៍ និងមេរៀនដើម្បីបន្តកែលំអ។ ខ្ញុំក៏មានទំនុកចិត្តដែរថា លោកជំទាវ ឯកឧត្តម លោកស្រី លោក ទាំងអស់នឹងរីករាយក្នុងការចូលរួមពិភាក្សាដោយផុសផុលក្នុងរយៈពេលពីរថ្ងៃនេះ។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ លោកជំទាវ ឯកឧត្តម លោកស្រី លោក ទាំងអស់ចំពោះការខិតខំប្រឹងប្រែង និង ការចំណាយពេលវេលាដ៏មានតំលៃដើម្បីចូលរួមកិច្ចប្រជុំនេះ។ ខ្ញុំសូមជូនពរឱ្យការពិភាក្សាប្រព្រឹត្តទៅដោយផ្លែផ្កា និងទទួលបាននូវលទ្ធផលល្អ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....................សហវ.....

# Public Financial Management Reform Program
# 2006 Annual Review

## Opening Remarks

**By H.E. Mr. Keat Chhon**
**Senior Minister and Minister of Economy and Finance**
**Siem Reap, 09th April 2007**

***Excellency Ladies and Gentleman,***

It is a great honor and pleasure for me to be here with all of you at this important event, the, "Second Annual Review of the Public Financial Management Reform Program". I would like to personally thank Excellencies, Ladies, and Gentlemen for giving up your valuable time and for making the effort to participate in this annual review especially for senior management of the Government and Development Partners for their active engagement and support. Special thanks go to the Public Financial Management Technical Working Group (PFMTWG), the Reform Committee (RC), and the Development Partner Committee (DPC) for their hard work and preparation for this annual review.

I want to take this opportunity to reconfirm Government commitment to this reform program, which has continued to strengthen because of sustained support from both Government and Legislative bodies. I ensure on a regular basis that my colleagues in Cabinet are aware of our plans and progress, and as a result our program continues to benefit from their encouragement and their active support and engagement. Moreover, stakeholders' awareness and shared understanding, especially among senior management, has increased due to being regularly informed and their greater participation in the program. As a result, the sequential nature of our activities and platforms have become more clearer and meaningful to more stakeholders enabling the reform program to achieve concrete results, I am certain that our commitment, ownership, responsibility and our confidence will continue to grow, as we witness the benefits of our reforms.



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92. Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

In addition, it is clear that Public Financial Management Reform is not only the heart of good governance, but also a vital vehicle for achieving other government policy objectives especially the Rectangular Strategy (RS) and for successful implementation of the National Strategic Development Plan (NSDP). Making the budget more credible means securing sustainable inflow of revenue and ensuring a smooth outflow of expenditure to meet ministries' needs for achieving RGC's policy objectives. Though it may be premature to declare a victory of platform one, which we are going to discuss during the next two days at this Review, I would say with confidence that the budget is more credible now than last year and two years ago, which means that we have been able to provide more and more opportunity for ministries to achieve their policy objectives.

***Excellency Ladies and Gentleman,***

In moving to the subsequent platforms, that focus on accountability, transparency, performance measurement and monitoring, I envisage a long list of complex tasks including technical/institutional and capacity development measures that Line Ministries will have to address in order to ensure that more resource availability and more financial power that we have been delegating to them will be used effectively and efficiently. I am sure representatives from some of the key ministries here will raise these issues in their presentation on the perspective of Line Ministries. Therefore, my message to Line Ministries is that participation and cooperation from Line Ministries are not enough, it requires ownership and responsibility with Line ministries being proactive to ensure successful implementation of the Public Financial Management Reform Program.

It is worthwhile to emphasize again that good partnership, good cooperation, and well coordinated processes between government and development partners, among government ministries and agencies and between development partners themselves are also crucially important for the success of this comprehensive and complex reform program. However, it is also important to make sure that we do not use assistance and support to drive away our ownership and responsibility. In this context, I would like to warmly welcome and highly recognize the keen international interest and kind support which our Development Partners have been providing to us towards achieving our ambitious objectives. The Royal Government of Cambodia strongly anticipates that this approach will provide favorable and fruitful results and will also become an outstanding model for promoting the development, monitoring and managing the implementation of the reform program in other sectors.

Progress and achievements have been made, but we still have a long path to tread and we also know that we will continue to face more challenges and difficult decisions to take which we are determined not to shrink from. These demonstrate commitments, ownership, responsibilities,

and joint efforts of management and officials of the Ministry of Economy and Finance and other involved ministries and institutions including the strong support and commitment from our development partners.

***Excellencies Ladies and gentlemen,***

Experience has been learnt and is being used to improve the implementation of the reform program toward an increasingly effective and efficient result. I think that the important strengths of the program which are worth highlighting here are:

(i) Strong commitment of both Government and Development Partners,

(ii) Ownership and responsibility of the MEF management, and officials, as well as active support and participation of concerned line ministries and agencies.

(iii) Good coordination and monitoring framework within the SWAp modality, and

(iv) Clear and comprehensive strategic implementation with platform approach.

The Public Financial Management Reform Program is a central plank underlying the general administrative reform program. Achievement of the 2015 vision is underpinned by the Government's commitment to establishing the framework for a professional civil service, in which officials will be able to maintain Public Financial Management standards without depending on continuous external advice. Public Financial Management Reform and the transformation of the civil service will have to become increasingly linked and mutually supportive in the progress towards the vision of installing much higher standards of management and accountability, transparency., and responsibility for mobilizing all government resources and effectiveness and efficiency in their application to the Government's Rectangular Strategy (RS) and National Strategic Development Plan (NSDP).

I strongly believe that this second annual review is an important opportunity for us to share experience and lessons for further improvement. I am also confident that you will all enjoy an active and productive discussion throughout the review program. Once again, I would like to thank all of you for your time and efforts in participating in this review and I wish for a fruitful discussion and successful outcome.